# II- រាជរដ្ឋាភិបាល

## ១ - អនុក្រឹត្យ

### អនុក្រឹត្យលេខ ៣៤ អនក្រ.បក

### ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃ ទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី និងនាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រម លេខ ០២ ន.ស . ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ស្តីពីការរៀ និង ការប្រព្រឹត្តទៅ របស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ន.ស/ រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ន.ស/រកត/១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម នស/រកម/១០៩៦/១៥ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពី បង្កើតក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ/បក ចុះថ្ងៃទី ៣០ ខែ មេសាឆ្នាំ ១៩៩៦ ស្តីពីការរៀ និងការ ប្រព្រឹត្តទៅ របស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍
- តាមការអនុម័តរបស់គណៈរដ្ឋមន្ត្រីថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៩៧

**សំរេច**

### ជំពូក ១

### បទបញ្ញត្តិទូទៅ

**មាត្រា ១** .- អនុក្រឹត្យនេះរៀបចំបណ្តាអង្គភាពនៃក្រសួងទេសចរណ៍ និងកំណត់បេសកកម្មរបស់ក្រ និងមុខការនៃអគ្គនាយកដ្ឋាន និងនាយកដ្ឋាននានា ។

## ជំពូក ២

## បេសកកម្ម និង រចនាសម្ព័ន្ធ

មាត្រា ២ .- ក្រសួងទេសចរណ៍ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ប្រគល់បេសកកម្មឱ្យដឹកនាំ និងគ្រប់គ្រងវិស័យទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣ .- ក្រសួងទេសចរណ៍ មានមុខងារនិងភារកិច្ចដូចតទៅ :

- កំណត់នយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យទេសចរណ៍ និងរៀបចំផែនការអភិវឌ្ឍន៍ទេសចរណ៍
- ជំរុញលើកទឹកចិត្តការងារវិនិយោគទុន ក្នុងវិស័យទេសចរណ៍ ដោយយោងលើការអភិវឌ្ឍន៍ជា យុទ្ធសាស្ត្ររបស់ជាតិ
- រៀបចំគ្រប់គ្រងវិស័យឧស្សាហកម្មទេសចរណ៍
- តំរង់ទិសនិងត្រួតពិនិត្យរាល់សេវា ដែលបំរើឱ្យវិស័យទេសចរណ៍
- កំណត់រៀបចំតំរង់ទិស ត្រួតពិនិត្យ និងថែរក្សារមណីយដ្ឋានធម្មជាតិ រមណីយដ្ឋានកែច្នៃទេសចរណ៍នានា មណ្ឌលទេសចរណ៍ តំបន់អភិវឌ្ឍន៍ទេសចរណ៍ ក្នុងព្រះរាជាណាចក្រកម្ពុជា
- សិក្សាសំណើសុំបង្កើត ទទួលស្គាល់និងត្រួតពិនិត្យសាលាឯកជន និងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ បំរើឱ្យវិស័យទេសចរណ៍
- ធ្វើការផ្សព្វផ្សាយវិស័យទេសចរណ៍ ក្នុងនិងក្រៅប្រទេស
- ចាត់តំណាងនៅក្រៅប្រទេសដោយសហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ចុះហត្ថលេខាលើកិច្ចសន្យាអនុវត្តនានា ដែលទាក់ទងទៅលើវិស័យទេសចរណ៍ក្រោយពីបានគោលការពីរាជរដ្ឋាភិបាល
- ចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មដល់ក្រុមហ៊ុនទេសចរណ៍ ទីភ្នាក់ងារទេសចរណ៍ និងមគ្គ

ពិនិត្យលើសេវាទេសចរណ៍និងអាជីវកម្មផ្សេងៗទៀតដែលទាក់ទងនឹងវិស័យទេសចរណ៍

អធិការកិច្ចវិស័យទេសចរណ៍ ។

ក្រសួងទេសចរណ៍មានរចនាសម្ព័ន្ធ ដូចតទៅ :

- ខុទ្ទកាល័យរដ្ឋមន្ត្រី
- អធិការដ្ឋាន

- នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានទេសចរណ៍
- អង្គភាពមូលដ្ឋាន ។

អង្គការលេខរបស់ក្រសួងទេសចរណ៍ ជាឧបសម្ព័ន្ធរបស់អនុក្រឹត្យនេះ ។

## ជំពូក ៣

## ខុទ្ទកាល័យរដ្ឋមន្ត្រី

**មាត្រា ៥ .-** ខុទ្ទកាល័យរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មទាំងឡាយ ដែលកំណត់តាមបទបញ្ញត្តិនៃអនុ លេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ដូចមានយោងក្នុងមូលបទខា ស្តីពីការ រៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ។

## ជំពូក ៤

## អធិការដ្ឋាន

**មាត្រា ៦ .-** អធិការដ្ឋានរបស់ក្រសួងទេសចរណ៍ ទទួលបន្ទុក :

- ធ្វើអធិការកិច្ចជាប្រចាំ ទៅលើគ្រប់អង្គភាពក្រោមឱវាទក្រសួងទេសចរណ៍
- ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រី ពីការប្រព្រឹត្តិទៅរបស់អង្គភាព ដែលបានធ្វើអធិការកិច្ច នោះ និងពីមធ្យោបាយកែលំអការប្រព្រឹត្តិទៅ របស់អង្គភាពទាំងនោះ
- ប្រតិបត្តិភារកិច្ចតាមការដែលរដ្ឋមន្ត្រីបានប្រគល់ទុកចិត្ត ។ អធិការដ្ឋានដឹកនាំដោយអធិក មួយនាក់អាច អមដោយអធិការរងមួយរូប ឬច្រើនរូបជួយធ្វើការទៅតាមការចាំបាច់ ។

## ជំពូក ៥

## នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

**មាត្រា ៧ .-** នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុទទួលបន្ទុក :

ក.-ក្នុងវិស័យរដ្ឋបាល

- សំរបសំរួលសកម្មភាពគ្រប់ផ្នែករបស់ក្រសួងនៅថ្នាក់កណ្តាល និងរវាងថ្នាក់កណ្តាល និ ភាពមូលដ្ឋានក្រោមឱវាទ
- គ្រប់គ្រងនិងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួង
- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល និងគ្រប់គ្រងការងារសង្គមរបស់ក្រសួង
- សរុបនិងធ្វើរបាយការណ៍ការងារនិងសកម្មភាពផ្សេងៗរបស់ក្រសួង ។

ខ- ក្នុងវិស័យគ្រប់គ្រងបុគ្គលិក

- គ្រប់គ្រងផ្នែករដ្ឋបាល មន្ត្រីរាជការ និងភ្នាក់ងាររាជការរបស់ក្រសួង ដោយទំនាក់ទំនង និងរដ្ឋ លេខាធិការដ្ឋានមុខងារសាធារណៈ
- រៀបចំរាល់លិខិតរដ្ឋបាល សំរាប់ការគ្រប់គ្រងអាជីព
- ធ្វើកម្មវិធីពីតំណែងឯកទេស និងធនធានមនុស្សរបស់ក្រសួង
- វាយតម្លៃតម្រូវការក្នុងការបណ្តុះបណ្តាលបុគ្គលិក
- រៀបចំនយោបាយបណ្តុះបណ្តាលដំបូងនិងបន្ត ដោយទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងអនុវត្តនីនយោបាយនោះ
- រៀបចំស្ថិតិលើការគ្រប់គ្រងបុគ្គលិក និងតារាងពត៌មានប្រតិបត្តិ ។

គ- ក្នុងវិស័យគ្រប់គ្រងសំភារៈ និងបរិក្ខារ

- ប្រមូលផ្តុំតម្រូវការធ្វើកម្មវិធីចំណាយគ្រប់គ្រង ការរៀបចំផ្គូសផុលសំភារៈ និងបរិក្ខាររបស់ក្រសួង
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសំភារៈនិងធ្វើបញ្ជីសារពើភ័ណ្ឌ
- គ្រប់គ្រងយានដ្ឋាន និងយានយន្តរបស់រដ្ឋដែលប្រគល់ជូនក្រសួងព្រមទាំងធ្វើកម្មវិធីចំណាយ និងបែងចែកប្រេងឥន្ធនៈ និងគ្រឿងបន្លាស់
- ទទួលនិងបែងចែកបរិក្ខារជូនដល់បណ្តាអង្គភាពខេត្ត ក្រុងនានា
- កាន់បញ្ជីជាប្រចាំនូវសាលាកប័ត្រ និងគណនេយ្យរូបធាតុ
- ពត៌មានវិទ្យា សកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី
- ត្រួតពិនិត្យបច្ចេកទេសនៃការប្រតិបត្តិ លទ្ធកម្មសាធារណៈ ។

ឃ-ក្នុងវិស័យគ្រប់គ្រងបន្ទុកគណនីនិងហិរញ្ញវត្ថុ

- លើកគំរោងថវិកាក្រសួង និងតាមដានលើកពីការប្រតិបត្តិ
- គ្រប់គ្រងចំណូល ចំណាយឱ្យបានសមស្របតាមច្បាប់ហិរញ្ញវត្ថុ
- ប្រមូលផ្តុំនិងសំរបសំរួលជំពូកថវិកា
- តាមដានលើកការគ្រប់គ្រងគណនីពិសេស
- ប្រមូលផ្តុំនិងសំរបសំរួលរាល់ការចំណាយរបស់ក្រសួង
- គ្រប់គ្រងបន្ទុកគណនីរបស់ការអនុវត្តនៃលទ្ធកម្មសាធារណៈ ។

## ជំពូក ៦

## អគ្គនាយកដ្ឋានទេសចរណ៍

**មាត្រា ៨ .-** អគ្គនាយកដ្ឋានទេសចរណ៍ ទទួលបន្ទុកធ្វើការទំនាក់ទំនងសំរបសំរួលគ្រប់គ្រងការងារសិក្សាទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍ ផែនការអភិវឌ្ឍន៍ អប់រំបណ្តុះបណ្តាល អភិវឌ្ឍន៍ទេសចរណ៍វប្បធម៌ និងឧស្សាហកម្មទេសចរណ៍ ។ អគ្គនាយកដ្ឋានទេសចរណ៍ ដឹកនាំដោយអគ្គនាយកមួយរូបដែលអាចអមដោយ អគ្គនាយករងជាជំនួយការ តាមការចាំបាច់ អគ្គនាយកដ្ឋាននេះមាននាយកដ្ឋានចំណុះចំនួន ០៥ ដូចតទៅ ៖

- នាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍
- នាយកដ្ឋានផែនការអភិវឌ្ឍន៍
- នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍វប្បធម៌
- នាយកដ្ឋានអប់រំបណ្តុះបណ្តាល
- នាយកដ្ឋានឧស្សាហកម្មទេសចរណ៍ ។

**មាត្រា ៩ .-** នាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ទទួលបន្ទុក ៖

ក. ការងារសិក្សាទីផ្សារ

- ប្រមូលផ្តុំពត៌មាន និងធ្វើស្ថិតិដើម្បីធ្វើការវិភាគ
- ចងក្រងឯកសារដែលទាក់ទងទៅនឹងវិស័យទេសចរណ៍
- លើកកំពស់កំរិតផ្សព្វផ្សាយពត៌មានដល់អ្នកទេសចរណ៍
- គិតគូរកែលំអការស្វាគមន៍ដល់ភ្ញៀវទេសចរណ៍
- សហការជាមួយក្រុមហ៊ុនដឹកជញ្ជូននានា ដើម្បីប្រមូលពត៌មានជារៀងរាល់ថ្ងៃពីការធ្វើដំណើរ ហើយកត់ត្រានិងជូនដំណឹងដល់ភ្ញៀវទេសចរណ៍ជាបន្ទាន់ក្នុងករណីដែលមានការផ្លាស់ប្តូរក្នុងការ ធ្វើដំណើរ ។

ខ. ការងារផ្សព្វផ្សាយ

- រក្សាឱ្យបានជាអចិន្ត្រៃយ៍នូវការប្រាស្រ័យ និងនូវទំនាក់ទំនងរវាងនាយកដ្ឋាន ជាមួយភ្នាក់ងារតំណាងនៅក្រៅប្រទេសដែលទទួលបន្ទុកការងារផ្សព្វផ្សាយពត៌មានដោយគោរពរក្សានូវវប្បធម៌ប្រពៃណីជាតិ
- ទំនាក់ទំនងជាមួយនិងសារពត៌មានជាតិ និងអន្តរជាតិដែលមានប្រចាំនៅប្រទេសកម្ពុជាហើយ និងបណ្តាញឃោសនាបរទេសសំខាន់ៗ

- រៀបចំនិងចូលរួមក្នុងពិព័រណ៍អន្តរជាតិនានា
- គ្រប់គ្រងភ្នាក់ងារតំណាងនៅបរទេស
- ផ្សព្វផ្សាយពត៌មានដល់អ្នកទេសចរណ៍
- ផលិតឯកសារផ្សព្វផ្សាយនានា ។

**មាត្រា១០ .-** នាយកដ្ឋានផែនការអភិវឌ្ឍន៍ទទួលបន្ទុក :

- គ្រប់គ្រងពត៌មាន និងស្ថិតិទាក់ទងលើវិស័យទេសចរណ៍
- សិក្សាការអនុវត្តន៍ កំណត់ការរៀបចំទិន្នន័យនិងលើកគំរោងអភិវឌ្ឍន៍លើវិស័យទេសចរណ៍
- សិក្សាស្រាវជ្រាវលើកិច្ចសហប្រតិបត្តិការអន្តរជាតិ
- គ្រប់គ្រងកម្មវិធីជំនួយអន្តរជាតិ ។

**មាត្រា១១ .-** នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍វប្បធម៌ទទួលបន្ទុក :

- សហការជាមួយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាមួយអាជ្ញាធរនានាក្នុងការអភិវឌ្ឍន៍លើ វិស័យទេសចរណ៍វប្បធម៌
- សហការជាមួយនាយកដ្ឋានផែនការអភិវឌ្ឍន៍ដើម្បីសិក្សាស្រាវជ្រាវតំបន់ទេសចរណ៍នៅ ព្រះរាជាណាចក្រកម្ពុជា
- ថែរក្សាអត្តសញ្ញាណជាតិនិងតម្លៃវប្បធម៌ជាតិក្នុងកិច្ចអភិវឌ្ឍន៍វិស័យទេសចរណ៍ ។

**មាត្រា១២ .-** នាយកដ្ឋានអប់រំបណ្ដុះបណ្ដាលទទួលបន្ទុក :

- តំរង់ទិសក្នុងការបណ្ដុះបណ្ដាលហ្វឹកហ្វឺន មុខវិជ្ជាជីវៈទេសចរណ៍និងសេវាកម្មផ្សេងៗទៀត ដែលបំរើឱ្យវិស័យទេសចរណ៍តាមកាលៈទេសៈតំរូវការ និងធ្វើឱ្យសំរេចការងារនេះ
- ត្រួតពិនិត្យសាលាឯកជនដែលបណ្ដុះបណ្ដាលជាទូទៅនូវវិស័យទេសចរណ៍ ដោយសំរបសំរួលជាមួយក្រសួងអប់រំយុវជននិងកីឡា ។

**មាត្រា១៣ .-** នាយកដ្ឋានឧស្សាហកម្មទេសចរណ៍ទទួលបន្ទុក :

- ពិនិត្យសំណើសុំច្បាប់អនុញ្ញាតប្រកបអាជីវកម្ម ក្រុមហ៊ុនទេសចរណ៍ ទីភ្នាក់ងារទេសចរណ៍ និងមគ្គុទ្ទេសក៍ទេសចរណ៍
- សហការជាមួយនាយកដ្ឋានពាក់ព័ន្ធមន្ទីរទេសចរណ៍ខេត្ត-ក្រុងនិងអាជ្ញាធរមានសមត្ថកិច្ចដើម្បី ចាត់តាំងត្រួតពិនិត្យមូលដ្ឋានអាជីវកម្មសេវាកម្មដទៃទៀត ដែលទាក់ទងនិងវិស័យទេសចរណ៍ ។

## ជំពូក ៧

## អង្គភាពមូលដ្ឋាន

**មាត្រា១៤ ..** នៅតាមខេត្ត-ក្រុងនីមួយៗ មានមន្ទីរទេសចរណ៍ខេត្ត-ក្រុងនិងរចនាសម្ព័ន្ធខ្សែបណ្តោយតាមថ្នាក់ខ័ណ្ឌ ស្រុកដែលទទួលបន្ទុកអនុវត្តនិងសំរបសំរួលសកម្មភាពរបស់ក្រសួង ។

## ជំពូក ៨

## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា១៥ ..** អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុត្រូវបានបង្កើតឡើង ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមល័ក្ខខ័ណ្ឌនៃបទបញ្ជាកំណត់ក្នុងអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកាក្នុងបណ្តាក្រសួង ។

## ជំពូក ៩

## អវសានបញ្ញត្តិ

**មាត្រា១៦ ..** ការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងនៅរដ្ឋបាលកណ្តាល ចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ។

**មាត្រា១៧ ..** បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា១៨ ..** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រី និងរដ្ឋលេខា ធិការទាំងអស់ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុករៀងៗខ្លួនអនុវត្តអនុក្រឹត្យនេះដែលចូល ជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រីទី២

រដ្ឋលេខាធិការក្រសួងទេសចរ

ហត្ថលេខា : **ថោង ខុន**

## ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៣៤ អនក្រ បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧

## អង្គការលេខ របស់ក្រសួងទេសចរណ៍




* * *

## អនុក្រឹត្យ លេខ ៣៥ អនក្រ.បក

## ស្តីពីការបង្កើតស្រុកសំឡូតចំណុះខេត្តបាត់ដំបង

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

ឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី